## ៥. គ្រុបខំណន្ទកម្មវិធីបារអាទិភាព

## ៥.១. អាទិភាពកម្មវិធីចំណាយចរន្ត

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-០៥ បានសំរេចជោគជ័យយ៉ាងធំធេងក្នុងការផ្សារភ្ជាប់គោលនយោបាយ និងអាទិភាពជាយុទ្ធសាស្ត្រទៅនឹងកម្មវិធីជាអាទិភាពចរន្ត និងការបែងចែកថវិកា។ កម្មវិធីទាំងនេះបានផ្តល់លទ្ធផលនិងអាំងឌីកាទ័របំពេញការងារជាច្រើន ធ្វើជាមូលដ្ឋានសំរាប់ការពិនិត្យតាមដានគោលនយោបាយ និងកម្មវិធី។ ផែនការនិងកម្មវិធីមុនៗបានកំណត់អោយមានការកែសំរួលលើអាទិភាពជាយុទ្ធសាស្ត្រ យុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទាន និងការគ្រប់គ្រងថវិកា។ ការកែលំអនេះទាមទារអោយមានការផ្លាស់ប្តូរអាទិភាពកម្មវិធីចរន្ត និងការបែងចែកថវិកា ។ លក្ខណៈចំបងៗរួមមាន :

- ការបំបែកសមាសភាពផ្នែកអភិវឌ្ឍ និងគាំពារកុមារតូចចេញពីកម្មវិធីគុណភាព និងប្រសិទ្ធភាពអប់រំនៅបឋមសិក្សា និងការបង្កើតកម្មវិធីថ្មី ស្តីពីការអភិវឌ្ឍ និងគាំពារកុមារតូច។ ធ្វើដូចនេះ នឹងអាចអោយយុទ្ធសាស្ត្រកាន់តែមានភាពច្បាស់លាស់ និងការគ្រប់គ្រងកម្មវិធីកាន់តែមានប្រសិទ្ធភាព ។
- ការបំបែកកម្មវិធីគុណភាព និងប្រសិទ្ធភាពអប់រំមធ្យមសិក្សាជាពីរកម្មវិធី គឺមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ។ ការបំបែកកម្មវិធីជាពីរនេះដើម្បីអោយរាជរដ្ឋាភិបាលអនុម័តយកយុទ្ធសាស្ត្រហិរញ្ញប្បទានសមស្របនានាសំរាប់កំរិតទាំងពីរនេះ ។
- ការបញ្ចូលកម្មវិធីសៀវភៅសិក្សាគោលទៅក្នុងកម្មវិធីរបស់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ។ សនិទានកម្មនៃកម្មវិធីនេះ នឹងធ្វើអោយមានស្វ័យភាពកាន់តែច្រើនឡើងនៅក្នុងការកសាងផែនការ និងគ្រប់គ្រងកម្មវិធី នៅក្នុងបរិបទនៃការធ្វើវិមជ្ឈការរបស់រាជរដ្ឋាភិបាល ។

ជាបន្ថែម ក្រសួងទទួលស្គាល់ថាត្រូវអនុវត្តនិងពង្រីកយុទ្ធសាស្ត្រដែលមានលក្ខណៈជាការងារឆ្លងផ្នែកឬឆ្លងវិស័យរយៈពេលមធ្យមអោយបានច្រើនអាស្រ័យទៅតាមធនធានដែលមាន។ មានសំណើថាកម្មវិធីយល់ដឹងអំពីជំងឺ HIV/AIDS ដ៏សំខាន់ នឹងត្រូវគ្រប់គ្រងតាមរយៈយន្តការថវិកាជាមូលធន ដោយធ្វើសហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធឯទៀត។ មានការគ្រោងទុកថា ការអភិវឌ្ឍនិងថែទាំកុមារតូច និងកម្មវិធីអាហារូបករណ៍សំរាប់កុមារក្រីក្រអាចពង្រីកបានតាមរយៈការគាំទ្រថវិកាជាមូលធនស្របគ្នា។ ទំហំនិងគោលដៅនៃកម្មវិធីទាំងនេះអាចធ្វើការកែសំរួលក្នុងរយៈពេលផែនការ ប្រសិនបើមានធនធានពីអ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាលបន្ថែមទៀត។

កម្មវិធីប្រសិទ្ធភាពសេវាអប់រំ គឺធានាសមធម៌នៃការផ្តល់សេវាអប់រំតាមរយៈការលុបបំបាត់ការចំណាយក្រៅផ្លូវការរបស់មាតាបិតាសិស្សនៅថ្នាក់ទី១-៩ ដោយបង្កើនបៀវត្សបុគ្គលិកផ្អែកលើការបំពេញការងារ។

លទ្ធផលមួយទៀតគឺ ការកែលំអសមធម៌ និងប្រសិទ្ធភាពនៃការពង្រាយគ្រូបង្រៀន និងបុគ្គលិកមិនបង្រៀន អោយឆ្លើយតបទៅនឹងទិសដៅពង្រីកឱកាសទទួលការអប់រំនៅបឋមសិក្សា និងមធ្យមសិក្សា។សកម្មភាពសំខាន់ៗ រួមមាន ការផ្តល់រង្វាន់លើកទឹកចិត្តផ្អែកលើការបំពេញការងារដល់មន្ត្រីសំខាន់ៗដូចជា នាយកសាលារៀន មន្ត្រីដែលបំរើការនៅតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាក គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនពីរវេន។ ក្រសួងអប់រំ យុវជន និងកីឡានឹងធ្វើការពិនិត្យឡើងវិញនូវគោលការណ៍ណែនាំស្តីពីការកំនត់ទិសដៅនិងការបែងចែកថវិកាសំរាប់រង្វាន់លើកទឹកចិត្តទាំងនេះ។ កម្មវិធីនឹងត្រូវគ្រប់គ្រងតាមរយៈអង្គភាពគ្រប់គ្រងថវិកាខេត្តដោយផ្អែកលើគោលការណ៍ណែនាំជ្រើសរើសបុគ្គលិកដែលបានឯកភាពហើយ និងមានការពិនិត្យតាមដានដោយនាយកដ្ឋានបុគ្គលិក ជាមួយនឹងការផ្ទេរការងារទៅការិយាល័យអប់រំស្រុកជាដំណាក់ៗ។ កម្មវិធីនេះនឹងត្រូវបង្គ្រប់បន្ថែមដោយការផ្តល់រង្វាន់លើកទឹកចិត្តដែលបានគ្រោងសំរាប់គ្រូបង្រៀន ។

កម្មវិធីអភិវឌ្ឍន៍និងគាំពារកុមារតូចនឹងពង្រីកឱកាសចូលរៀនដោយសមធម៌នៅក្នុងការអភិវឌ្ឍនិងគាំពារកុមារតូចសំរាប់កុមារអាយុ៥ឆ្នាំតែប៉ុណ្ណោះ ដោយផ្តោតលើឃុំទាំងឡាយណាដែលមានអត្រានៃការចូលរៀនយឺត និងអត្រាត្រួតថ្នាក់នៅបឋមសិក្សាខ្ពស់។ កម្មវិធីនេះនឹងត្រូវបញ្ចប់ក្នុងរយៈពេល២ទៅ៣ឆ្នាំខាងមុខ ហើយយុទ្ធសាស្រ្តលំអិតថ្មីទៀតនឹងត្រូវបានរៀបចំឡើង។ ទិសដៅយុទ្ធសាស្រ្តនាពេលអនាគត គឺតំរង់ឆ្ពោះទៅរកគោលវិធីដែលមានសហគមន៍ជួយគាំទ្រ និងគោលវិធីសិស្សមជ្ឈមណ្ឌលដែលធ្វើអោយមានក្តីសង្ឃឹមកាន់តែប្រសើរឡើង និងអាចទ្រទ្រង់បានល្អជាងប្រព័ន្ធមត្តេយ្យសិក្សានាពេលបច្ចុប្បន្ននេះ។ មានការរំពឹងទុកថាកម្មវិធីនេះនឹងត្រូវបង្គ្រប់បន្ថែមដោយអ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល រួមទាំងក្រុមប្រឹក្សាឃុំ-សង្កាត់ និងមាតាបិតា។ នាយកដ្ឋានអប់រំកុមារតូច នឹងទទួលខុសត្រូវលើការគ្រប់គ្រងយុទ្ធសាស្រ្តនិងការធានាគុណភាព ។

ផលសំរេចនៃកម្មវិធីកែលំអគុណភាព និងប្រសិទ្ធភាពអប់រំនៅបឋមសិក្សា ផ្អែកលើការបន្តបង្កើនការគាំទ្ររបស់រាជរដ្ឋាភិបាលសំរាប់ការចំណាយលើដំណើរការសាលារៀន គួបផ្សំនឹងការផ្តល់សំភារសិក្សាសំរាប់បឋមសិក្សា ។ សមាសភាគទី១ គឺការផ្តល់ថវិកាដំណើរការសាលារៀន នឹងត្រូវបានពង្រីកជាបន្តបន្ទាប់ដល់សាលាបឋមសិក្សានៅទូទាំងប្រទេស។ សមាសភាគទី២ គឺបន្តការបំប៉នសិស្សពីថ្នាក់ទី១-៦ ដោយមានការវាយតំលៃសិស្សជាដំណាក់ៗ និងការពិនិត្យតាមដានស្តង់ដាការសិក្សារបស់សិស្ស។ សមាសភាគទី៣ នឹងត្រូវបែងចែកថវិកាទៅឱ្យសាលារៀនដើម្បីទិញសំភារសិក្សាដើម្បីរក្សាបាននូវផលធៀបសិស្សម្នាក់សៀវភៅមួយក្បាល ។ ការណែនាំកម្មវិធី នឹងត្រូវកែសំរួលដើម្បីធានាអោយមានភាពទន់ភ្លន់ និងបំរុងប្រយ័ត្នខ្ពស់ដល់សាលារៀន។ មូលនិធិសំរាប់កម្មវិធីនឹងត្រូវគ្រប់គ្រងនិងបញ្ជូនទៅសាលារៀនដោយអង្គភាពគ្រប់គ្រងថវិកាស្រុកទាំងជាង១៨០។ នាយកដ្ឋានបឋមសិក្សា នឹងគ្រប់គ្រងការពិនិត្យតាមដានកម្មវិធីនេះ ។

វត្ថុបំណងនៃកម្មវិធីកែលំអគុណភាព និងប្រសិទ្ធភាព និងការចូលរៀននៅមធ្យមសិក្សាបឋមភូមិ គឺកាត់បន្ថយឧបសគ្គចូលរៀនរបស់សិស្ស បង្កើនអត្រាគង់វង្សនៅថ្នាក់ទី៧-៩ និងអត្រាឆ្លងភូមិសិក្សាទៅថ្នាក់ទី១០ ។ សមាសភាគ ទី១ គឺបង្កើនថវិកាដំណើរការសាលាមធ្យមសិក្សាបឋមភូមិនៅទូទាំងប្រទេស ។ សមាសភាគទី២គឺផ្តល់ថវិកាទៅសាលាមធ្យមសិក្សាបឋមភូមិសំរាប់ទិញសំភារសិក្សា ដើម្បីធានាបាននូវផលធៀបសិស្សសៀវភៅសិក្សា ១:១ ។ កម្មវិធីនេះ នឹងត្រូវផ្សារភ្ជាប់ទៅនឹងការពង្រីកសំភាររូបវ័ន្ត និងការពង្រាយគ្រូ និងការកែទំរង់ការងារបណ្តុះបណ្តាល ។ មូលនិធិសំរាប់កម្មវិធី នឹងត្រូវគ្រប់គ្រង និងបញ្ជូនទៅសាលារៀនដោយអង្គភាពគ្រប់គ្រងថវិកាស្រុកទាំងជាង ១៨០ ។ នាយកដ្ឋានមធ្យមសិក្សា នឹងគ្រប់គ្រងការពិនិត្យតាមដានកម្មវិធីនេះ ។

វត្ថុបំណងសំខាន់នៃកម្មវិធីសមធមិការចូលរៀននៅមធ្យមសិក្សាទុតិយភូមិ គឺធានាការចូលរៀនប្រកបដោយសមធមិ និងធានាថាមិនមានឧបសគ្គចំពោះការបង់ប្រាក់របស់សិស្សក្រីក្រថ្នាក់ទី៩ដែលបានប្រលងជាប់ ។ សមាសភាគទី១ គឺផ្តល់កញ្ចប់ថវិកាផ្អែកតាមសន្ទស្សន៍ភាពក្រីក្រដល់សាលារៀន សំរាប់ទិញសំភារៈសិក្សា និងការថែទាំសាលារៀន ស្របតាមគោលការណ៍ដែលបានឯកភាព។ មូលនិធិនឹងត្រូវចាត់ចែងតាមរយៈគណៈកម្មការគ្រប់គ្រងសាលារៀន-សហគមន៍ថ្មី និងបញ្ជូនតាមរយៈអង្គភាពគ្រប់គ្រងថវិកាខេត្ត។ នាយកដ្ឋានមធ្យមសិក្សា នឹងគ្រប់គ្រងការពិនិត្យតាមដាន កម្មវិធីនេះ ។

វត្ថុបំណងសំខាន់នៃកម្មវិធីចូលរៀននិងសមធមិនៅគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គឺធានាសមធមិក្នុងការទទួលការបណ្តុះបណ្តាលជំនាញពាក់ព័ន្ធសំរាប់សិស្សក្រីក្រ ដោយផ្តល់អាហារូបករណ៍ដល់ក្រុមគោលដៅ ដូចជា យុវជនក្រៅសាលា និងយុវជនអត់ការងារធ្វើ តាមចំនួនដែលបានកំណត់ ។ យុទ្ធសាស្ត្រកម្មវិធីលំអិត នឹងត្រូវបញ្ចប់ក្នុងពីរទៅបីខែខាងមុខ ។ មានការគ្រោងថា មូលនិធិនឹងត្រូវគ្រប់គ្រងតាមរយៈសមាសភាគរបស់មូលនិធិសំរាប់ការបណ្តុះបណ្តាលថ្នាក់ជាតិ (NTF) ក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាបណ្តុះបណ្តាលថ្នាក់ជាតិ (NTB) ដែលបានរៀបចំឡើងវិញ ។ យន្តការនៃការផ្តល់មូលធន អាចរួមទាំងការផ្តល់ប្រាក់អាហារូបករណ៍ដោយផ្ទាល់ឱ្យសិស្ស ឬផ្តល់ប័ណ្ណចំណាយដើម្បីទទួលឱកាសបណ្តុះបណ្តាលនៅស្ថាប័នឯកជន សហគ្រាសឯកជន ឬគំរោងតូចៗនៃការបណ្តុះបណ្តាលតាមបែបកូនជាង ។ កម្មវិធីនេះនឹងត្រូវអនុវត្តដោយមានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

វត្ថុបំណងនៃកម្មវិធីចូលរៀន និងសមធមិនៅឧត្តមសិក្សា គឺបង្កើនការចូលរៀននៅឧត្តមសិក្សាដោយលើកទឹកចិត្តតាមរយៈការផ្តល់អាហារូបករណ៍ដល់សិស្សពូកែមកពីគ្រួសារក្រីក្រ ។ ក្រុមគោលដៅ គឺសិស្សក្រីក្រដែលបានបញ្ចប់ការសិក្សាពីសាលាមធ្យមសិក្សាទុតិយភូមិគំរូ និងសិស្សមកពីជនបទ ដែលមានលក្ខណៈសម្បត្តិសមស្របចូលរៀននៅសកលវិទ្យាល័យនានានៅភ្នំពេញ។ អាទិភាពនឹងត្រូវផ្តល់អោយសិស្ស និស្សិតដែលចូលរៀនក្នុងកម្មវិធីដែលមានលក្ខណៈតំរង់ទៅទីផ្សារតិចតួច និងកម្មវិធីដែលមានផលប្រយោជន៍ដល់សង្គម ជាពិសេសគ្រូ

បង្រៀន ការអប់រំសុខភាព វិទ្យាសាស្ត្រ និងគណិតវិទ្យា ។ យុទ្ធសាស្ត្រលំអិតរបស់កម្មវិធី និងបែបបទផ្តល់ហិរញ្ញប្បទាន នឹងត្រូវបញ្ចប់ក្នុងចន្លោះពីរទៅបីខែក្រោយ ។ កម្មវិធីនេះ នឹងផ្សារភ្ជាប់ទៅនឹងមូលនិធិជាមូលធនអភិវឌ្ឍន៍ឧត្តមសិក្សាដែលបានស្នើ និងការបង្កើតគំរោងឥណទានសំរាប់និស្សិត ។ មូលនិធិត្រូវគ្រប់គ្រងដោយផ្ទាល់នៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលបានជ្រើសរើស ដោយផ្អែកលើការបែងចែកអាហារូបករណ៍ប្រចាំឆ្នាំ ផ្តល់តាមរយៈរតនាគារជាតិ ។ លក្ខណៈវិនិច្ឆ័យសមស្របសំរាប់គ្រឹះស្ថាន នឹងរួមបញ្ចូលនូវការវិវឌ្ឍជាមួយនឹងការធានាគុណភាព និងមានលក្ខណៈជាស្ថាប័នរដ្ឋបាលសាធារណៈ ។ ការពិនិត្យតាមដាន និងធានាគុណភាព នឹងត្រូវទទួលខុសត្រូវដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និងនាយកដ្ឋានឧត្តមសិក្សា ។

វត្ថុបំណងនៃកម្មវិធីអភិវឌ្ឍន៍គ្រូបង្រៀន គឺធានាផ្តល់គ្រូក៏រិតអប់រំមូលដ្ឋាន គ្រូមធ្យមសិក្សាទុតិយភូមិប្រកបដោយប្រសិទ្ធភាព សំរាប់ពង្រីកប្រព័ន្ធ និងលើកកំពស់សមត្ថភាពគ្រូឧទ្ទេសសាលាគរុកោសល្យ នាយកសាលារៀន និងមន្ត្រីសំខាន់ៗរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ វត្ថុបំណងទី២គឺធានាថាគរុសិស្ស គរុនិស្សិតថ្មីដែលបានជ្រើសរើស ព្រមទាំងការពង្រាយគ្រូជាបន្តបន្ទាប់ ឆ្លើយតបទៅនឹងកំណើននៃតំរូវការនៅតំបន់ជនបទ/ដាច់ស្រយាល ។ វត្ថុបំណងទី៣ គឺជ្រើសរើសគរុសិស្ស គរុនិស្សិត ពីតំបន់ដាច់ស្រយាល និងតំបន់ជនជាតិភាគតិចដែលលំបាកចាត់តាំងបុគ្គលិកទៅបំរើការ ។ វត្ថុបំណងទី៤គឺ ពង្រីកការធ្វើវិក្រឹត ការបំប៉នគ្រូ ។ សមាសភាគសំខាន់មួយ គឺចាប់ផ្តើមផ្តល់ថវិកាដំណើរការប្រចាំឆ្នាំដល់សាលាគរុកោសល្យ និងវិក្រឹតការខេត្ត-ក្រុងទាំង១៨ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦ ។ សមាសភាគទី២គឺ ចាប់ផ្តើមផ្តល់ថវិកាដំណើរការដល់វិទ្យាស្ថានជាតិអប់រំ និងសាលាគរុកោសល្យ និងវិក្រឹតការខ្នាតតូចចំនួន ៦ ដែលនឹងបង្កើតថ្មីនៅក្នុងខេត្ត-ក្រុងដែលគ្មានសាលាគរុកោសល្យ និងវិក្រិតការ ។ សមាសភាគទី៣គឺ ផ្ទេរជាបន្តបន្ទាប់នូវចំណាយក្នុងការធ្វើវិក្រិតការ បំប៉នគ្រូដែលកំពុងអនុវត្តសព្វថ្ងៃនេះទៅអោយខេត្ត-ក្រុង ។ កម្មវិធីនេះត្រូវផ្សារភ្ជាប់ទៅនឹងគំរោងផ្តល់ប្រាក់ឧបត្ថម្ភសំរាប់ទ្រទ្រង់ជីវភាព និងការស្នាក់នៅ និងទាំងពីរបញ្ចូលគ្នា ប្រសិនបើអាចធ្វើទៅបាន ។ ថវិកាប្រតិបត្តិការ នឹងត្រូវគ្រប់គ្រងដោយស្ថាប័នដោយឡែកៗផ្ទាល់ ហើយត្រូវបញ្ជូនអោយបានសមស្របតាមរយៈអង្គភាពគ្រប់គ្រងថវិកាថ្នាក់ខេត្ត និងនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ។ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នឹងទទួលខុសត្រូវលើការពិនិត្យតាមដាន និងធានាគុណភាព ។

លទ្ធផលនៃកម្មវិធីពង្រីកការអប់រំក្រៅប្រព័ន្ធ គឺផ្តល់ប្រសិទ្ធភាពចំណាយសំរាប់កម្មវិធីចូលរៀនឡើងវិញ និងកម្មវិធីបំពេញវិជ្ជា និងអក្ខរកម្ម និងកម្មវិធីបណ្តុះបណ្តាលជំនាញសហគមន៍ក្រៅប្រព័ន្ធដែលបានជ្រើសរើស ។ ក្រុមជនគោលដៅសំខាន់ គឺសិស្សដែលបានបោះបង់ការសិក្សាតិចជាង ៣ឆ្នាំ និងក្រុមជនដែលជួបការលំបាកខ្លាំងរស់នៅក្នុងតំបន់ដាច់ស្រយាល តំបន់ជនជាតិភាគតិច និងតំបន់តាមព្រំដែន ។ សមាសភាគទី១គឺ ផ្តល់ថវិកាដំណើរការសំរាប់ពង្រីកកម្មវិធីចូលរៀនឡើងវិញនៅថ្នាក់ទី៣-៩ ចំពោះសិស្សដែលបានបោះបង់ការសិក្សា ។

សមាសភាគទី២គឺ ផ្តល់មូលនិធិដំណើរការសំរាប់ពង្រីកកាលានុវត្តភាពក្នុងការទទួលការអប់រំតាមកម្មវិធីបំពេញវិជ្ជានិងអក្ខរកម្ម ទន្ទឹមនឹងការអភិវឌ្ឍកម្មវិធីសិក្សាបន្ថែមទៀតព្រមទាំងផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលជំនាញនៅអប់រំក្រៅប្រព័ន្ធ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍។ ការរៀបចំការគ្រប់គ្រងហិរញ្ញវត្ថុមិនទាន់បានបញ្ចប់នៅឡើយ។ ជំរើសនានារួមមាន មូលនិធិសំរាប់ការអប់រំក្រៅប្រព័ន្ធទៅតាមតំរូវការ ឬប្រើប្រាស់អង្គភាពគ្រប់គ្រងថវិកាខេត្តនិងស្រុក។ គោលការណ៍ណែនាំ នឹងធ្វើអោយមានភាពទន់ភ្លន់ និងទំនួលខុសត្រូវខ្ពស់ចំពោះតំរូវការជាអាទិភាព និងពង្រីកកម្មវិធីទៅដល់ក្រុមសហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលនានា។ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ នឹងទទួលខុសត្រូវលើការពិនិត្យតាមដាននិងធានាគុណភាពកម្មវិធី។

លទ្ធផលនៃកម្មវិធីអភិវឌ្ឍន៍យុវជន និងកីឡា គឺដើម្បីកែលំអកម្មវិធីអប់រំកាយ និងកីឡាអោយមានគុណភាពខ្ពស់នៅក្នុងតំបន់ជនបទ និងតំបន់ក្រីក្រ។សកម្មភាពសំខាន់មួយគឺ បន្តកម្មវិធីបណ្តុះបណ្តាលមន្រ្តីឯកទេសអប់រំកាយ និងគ្រូបង្វឹក អាជ្ញាកណ្តាល ។ សកម្មភាពសំខាន់មួយទៀតគឺ បន្តការកំណត់អាទិភាពសំរាប់ទីលានកីឡាថ្មី និងកែលំអទីលានដែលមានស្រាប់ ជាពិសេសនៅក្នុងតំបន់ជនបទដែលពុំទាន់បានផ្តល់។ សកម្មភាពខាងមុខទៀតគឺ សំរួលដល់កិច្ចសហប្រតិបត្តិការជាមួយផ្នែកឯកជន ក្នុងការផ្តល់មូលនិធិសំរាប់ការប្រកួតកីឡាជាលក្ខណៈជាតិ លក្ខណៈតំបន់ និងលក្ខណៈអន្តរជាតិ។ កម្មវិធីនឹងត្រូវគ្រប់គ្រងតាមរយៈអង្គភាពគ្រប់គ្រងថវិកាក្នុងនាយកដ្ឋានយុវជន និងកីឡា ។

កម្មវិធីពង្រឹងប្រព័ន្ធពិនិត្យតាមដាន មានទិសដៅកែលំអការពិនិត្យតាមដានបច្ចេកទេស និងហិរញ្ញវត្ថុ នៅគ្រប់កំរិត ដើម្បីអភិវឌ្ឍ គ្រប់គ្រង និងវាយតំលៃគោលនយោបាយ យុទ្ធសាស្រ្ត និងកម្មវិធីដែលបានពង្រឹង ។ សកម្មភាពជាអាទិភាពមួយនៅក្នុងអំឡុងនៃរយៈពេលនេះ គឺត្រូវពង្រឹងសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចបញ្ជីការគណនេយ្យ និងសវនកម្មផ្ទៃក្នុង ទន្ទឹមនឹងការធ្វើអោយប្រសើរឡើងនូវការពិនិត្យតាមដានការបំពេញការងារតាមវិស័យ និងប្រតិបត្តិការស្រាវជ្រាវ ។ កម្មវិធីនឹងត្រូវគ្រប់គ្រងតាមរយៈអង្គភាពគ្រប់គ្រងថវិកាថ្នាក់កណ្តាលក្នុងនាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានផែនការ និងនាយកដ្ឋាន-ការិយាល័យសវនកម្មផ្ទៃក្នុង ។ ការពិនិត្យតាមដានកម្មវិធី និងការធានាគុណភាព នឹងត្រូវទទួលខុសត្រូវរួមគ្នារវាងអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គាធិការដ្ឋាន ។

វត្ថុបំណងនៃកម្មវិធីអាហារូបករណ៍សំរាប់មធ្យមសិក្សាគឺ ធានាអោយមានសមាសភាពរបស់សិស្សពូកែនិងសិស្សមកពីគ្រួសារក្រីក្រ និងតំបន់ជួបការលំបាកកាន់តែច្រើនឡើង ជាពិសេសសិស្សស្រី និងជនជាតិភាគតិចតាមរយៈការបង្កើនចំនួនអាហារូបករណ៍បន្តិចម្តងៗសំរាប់សិស្សក្រីក្រ ។ សមាសភាគទីមួយគឺ ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាកនៅថ្នាក់ទី៧-៩។ សមាសភាគទីពីរ គឺផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រដែលរៀនពូកែទាំងនៅទីក្រុងនិងជនបទ ដោយផ្អែកលើលទ្ធផលនៃការប្រលងនៅថ្នាក់ទី៩ ព្រមទាំងផ្តល់អាហារូបករណ៍កំរិត

ខ្ពស់សំរាប់ការចូលរៀននៅសាលាមធ្យមសិក្សាទុតិយភូមិគំរូ។ សមាសភាគទីបីគឺ ផ្តល់អាហារូបករណ៍ដល់សិស្សពូកែនៅថ្នាក់ទី១០-១២ដែលរៀននៅសាលាគំរូ។ ការរៀបចំការគ្រប់គ្រងកម្មវិធីនៅមិនទាន់បានបញ្ចប់នៅឡើយ។

## ៥.២. អាទិភាពនៃកម្មវិធីមូលធន

ដូចដែលបានគូសបញ្ជាក់នៅក្នុងផ្នែកមុនៗ វត្ថុបំណងសំខាន់របស់ក្រសួង គឺពង្រឹងការផ្សារភ្ជាប់គោលនយោបាយរវាងកម្មវិធីថវិកាចរន្ត និងមូលធន តាមរយៈការរៀបចំឡើងវិញនូវការកសាងផែនការ និងការគ្រប់គ្រង ព្រមទាំងការពិនិត្យតាមដានកម្មវិធី។

ចំណោលថវិកានិយោគជាមូលធនសំរាប់ឆ្នាំ២០០៤-០៨ មានលំអិតជូននៅក្នុងតារាងខាងក្រោម ដែលរួមមានការអភិវឌ្ឍសំភាររូបវ័ន្ត និងការគាំទ្រដល់សេវា និងការផ្គត់ផ្គង់ ព្រមទាំងជំនួយបច្ចេកទេសសំរាប់ការកសាងសមត្ថភាព។ ថ្វីបើមិនបានដាក់បញ្ចូលទៅក្នុងអាទិភាពថវិកាមូលធនបច្ចុប្បន្នក៏ដោយ ការជួយគាំទ្របំពេញបន្ថែមពីសំណាក់អ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាល សំរាប់ការអភិវឌ្ឍ និងគាំពារកុមារតូច ហ៊ីវ-អេដស៍ និងកំរៃលើកទឹកចិត្ត អាហារូបករណ៍សំរាប់សិស្សក្រីក្រ អាចត្រូវបានដាក់បញ្ចូលជាមូលនិធិ ដែលបានកៀរគរប្រមូល។

លក្ខណៈពិសេសមួយនៃការវិនិយោគនេះ គឺការពង្រីកបរិមាណ និងប្រសិទ្ធភាពនៃការប្រើប្រាស់សំភាររូបវ័ន្តអប់រំមូលដ្ឋាន ដើម្បីដោះស្រាយអោយបាននូវសំណូមពរដែលចេះតែកើនឡើងនិងជួយធ្វើអោយសំរេចបាននូវការអប់រំសំរាប់ទាំងអស់គ្នា។ លក្ខណៈពិសេសមួយទៀតគឺ ត្រូវធ្វើអោយបានសំរេចទាំងការពង្រីកការចូលរៀន និងកំណែលំអគុណភាពនៅមធ្យមសិក្សាទុតិយភូមិ តាមរយៈការវិនិយោគលើសំភាររូបវ័ន្ត ដើម្បីឆ្លើយតបទៅនឹងតំរូវការ។ លក្ខណៈពិសេសមួយផ្សេងទៀតគឺ ត្រូវធ្វើអោយបានសំរេចទៅតាមសំណូមពរដែលចេះតែកើនឡើង នៅក្នុងផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងឧត្តមសិក្សា ដោយបង្កើនភាពជាដៃគូរវាងសាធារណៈ និងឯកជនអោយបានខ្លាំងក្លា។

**តារាង ៦ : ចំនោលថវិកាវិនិយោគមូលធន ២០០៤-០៨**

| សមាសភាគ | រៀល (លាន) | ដុល្លាអាមេរិក (លាន) |
|---|---:|---:|
| ០១- ការកាត់បន្ថយសាលារៀនមិនគ្រប់កំរិតថ្នាក់ | ២០,០០០ | ៥.០ |
| ០២- ការពង្រីកសាលាមធ្យមសិក្សាបឋមភូមិ | ១០០,០០០ | ២៥.០ |
| ០៣- ការពង្រីកសាលាមធ្យមសិក្សាទុតិយភូមិ | ៨០,០០០ | ២០.០ |
| ០៤- ការពង្រីកសំភាររូបវ័ន្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង ICT | ៣១,៦០០ | ៧.៩ |
| ០៥- ការអភិវឌ្ឍមន្ត្រីអប់រំ | ៣៨,០០០ | ៩.៥ |

| | | |
|---|---|---|
| ០៦- ការផ្តល់ផ្ទះស្នាក់នៅសំរាប់មន្ត្រីអប់រំ | ២០,០០០ | ៥.0 |
| ០៧- មូលនិធិអភិវឌ្ឍសំភាររូបវ័ន្ត TVET | ៤០,០០០ | ១០.0 |
| ០៨- មូលនិធិអភិវឌ្ឍសំភាររូបវ័ន្តគ្រឹះស្ថានឧត្តមសិក្សា | ៦០,០០០ | ១៥.0 |
| ០៩- កម្មវិធីកសាងសមត្ថភាព | ១៥០,០០០ | ៣៧.៥ |
| - ការគ្រប់គ្រង និងពិនិត្យតាមដានកម្មវិធី | ៧៥,០០០ | ១៨.៨ |
| - ការគ្រប់គ្រងទូទាំងវិស័យ | ៧៥,០០០ | ១៨.៨ |
| **សរុប** | **៥៣៩,៦០០** | **១៣៤.៩** |

ផលសំរេចនៃ*កម្មវិធីកាត់បន្ថយសាលារៀនមិនគ្រប់កំរិតថ្នាក់* គឺដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សា និងបង្កើនអត្រាឡើងថ្នាក់ នៅតាមសាលាបឋមសិក្សាមិនគ្រប់កំរិតថ្នាក់ទាំងនោះ ជាពិសេសសាលាឧបសម្ព័ន្ធ និងសាលានៅតាមតំបន់ដាច់ស្រយាល។ សកម្មភាពសំខាន់ៗរួមមាន សាងសង់បន្ទប់រៀន ១, ២ ឬ ៣បន្ទប់ទៀត និងមានបំពាក់គ្រឿងសង្ហារឹម។ កម្មវិធីនេះត្រូវផ្សារភ្ជាប់គ្នាទៅនឹងយុទ្ធសាស្ត្រនានារួមមាន ការពង្រាយបុគ្គលិក និងការផ្តល់រង្វាន់លើកទឹកចិត្ត កម្មវិធីដែលជាគោលដៅសំរាប់សិស្សក្រីក្រ (ឧ. កម្មវិធីផ្តល់អាហារសំរន់នៅតាមសាលារៀន) ការបង្រៀនថ្នាក់គួប ឬការបង្រៀនពីរវេន ព្រមទាំងយុទ្ធសាស្ត្រ សំរាប់ពង្រីកការចូលរៀនប្រកបដោយសមធម៌នៅកំរិតអប់រំមូលដ្ឋាន។ ចំណាយសំរាប់កម្មវិធីនេះគឺ ២០ពាន់លានរៀលសំរាប់រយៈពេល ៥ឆ្នាំ។

ផលសំរេចនៃ*កម្មវិធីពង្រីកសាលាមធ្យមសិក្សាបឋមភូមិ* គឺដើម្បីអោយមានបន្ទប់រៀនគ្រប់គ្រាន់សំរាប់ថ្នាក់ទី៧-៩ ដែលឆ្លើយតបទៅនឹងកំណើនតំរូវការនៅក្នុងរយៈពេល ៥ឆ្នាំ។ សមាសភាគទី១នៃកម្មវិធីនេះ គឺបង្កើតសាលារៀនអប់រំមូលដ្ឋាន ដែលមានពីថ្នាក់ទី១-៩ នៅក្នុងសាលាបឋមសិក្សាដែលមានសំភាររូបវ័ន្ត ប្រើមិនទាន់អស់លទ្ធភាព។ សមាសភាគទី២ គឺផ្តល់បន្ទប់រៀនថ្មីពីថ្នាក់ទី៧-៩ នៅតាមឃុំដែលមិនទាន់មាន ហើយបន្ទប់រៀននេះ ត្រូវសាងសង់នៅក្នុងបរិវេណសាលាបឋមសិក្សា ។ សមាសភាគទី៣ គឺការពង្រីកអនុវិទ្យាល័យបច្ចុប្បន្ន ដោយផ្អែកលើតំរូវការជាក់ស្តែង។ សមាសភាគចុងក្រោយ គឺផ្តល់អន្តេវាសិកដ្ឋាន និងបន្ទប់រៀនពីថ្នាក់ទី៧-៩ នៅតាមតំបន់ដែលមានរបាយប្រជាជនទាប (ឧ. តំបន់ជនជាតិភាគតិច)។ យុទ្ធសាស្ត្ររួមនៃការផ្តល់សំភាររូបវ័ន្តសិក្សា គឺផ្តល់បន្ទប់រៀនដែលគ្រោងឡើងទៅតាមស្តង់ដាក្រសួងអប់រំ យុវជន និងកីឡាចំនួន៥០% សំរាប់តំបន់ប្រជុំជន និងសាលារៀនខ្នាតតូចចំនួន៥០% នៅតាមតំបន់ជនបទនិងតំបន់ដាច់ស្រយាល។ ចំណាយសំរាប់កម្មវិធីនេះគឺ ១០០ពាន់លានរៀលក្នុងរយៈពេល៥ឆ្នាំ។

ផលសំរេចនៃ*កម្មវិធីពង្រីកសាលាមធ្យមសិក្សាទុតិយភូមិ* គឺដើម្បីបង្កើនការចូលរៀនតាមរយៈភាពជាដៃគូសាធារណៈ-ឯកជន ទាំងនៅក្នុងបរិបទនៃតំរូវការទីផ្សារពលកម្ម និងយុទ្ធសាស្ត្រសំរាប់ការអប់រំក្រោយកំរិតមូលដ្ឋាន។ សមាសភាគទី១សំរាប់កម្មវិធីនេះ គឺបង្កើតសាលារៀនគំរូចំនួន ៣០ តាមរយៈការលើកកំពស់សាលាមធ្យមសិក្សាទុតិយភូមិដែលមានស្រាប់ក្នុងខេត្ត-ក្រុងទាំង២៤។សាលារៀនគំរូទាំងនោះត្រូវបានផ្តល់សំភារបរិក្ខារព្រមទាំងបុគ្គលិកបង្រៀនដែលមានស្តង់ដាខ្ពស់។ សមាសភាគទី២ គឺការពង្រីកជាបណ្តើរៗសំភាររូបវ័ន្តសាលាមធ្យមសិក្សាទុតិយភូមិនៅតាមតំបន់ជនបទ តាមរយៈការពង្រីកសាលាដែលមានស្រាប់ ព្រមគ្នានឹងការផ្តល់សាលារៀនបន្ថែមនៅតាមតំបន់ដែលពុំទាន់មាន និងមានតំរូវការខ្ពស់។ ចំណាយសំរាប់កម្មវិធីនេះគឺ ៨០ពាន់លានរៀលក្នុងរយៈពេល ៥ ឆ្នាំ។

ផលសំរេចនៃ *កម្មវិធីពង្រីកសំភាររូបវ័ន្តសំរាប់ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង ICT* មានវត្ថុបំណងចំបងគឺធ្វើអោយប្រសើរឡើងនូវផលសំរេចនៃគុណភាពអប់រំ តាមរយៈការផ្តល់សំភាររូបវ័ន្តសមស្របសំរាប់ការបង្រៀននិងរៀន។ កម្មវិធីនឹងផ្តល់សំភាររូបវ័ន្តទាំងនោះសំរាប់សាលាមធ្យមសិក្សាទុតិយភូមិ មជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រឹះស្ថានឧត្តមសិក្សា។ ចំណាយសំរាប់កម្មវិធីនេះគឺ ៣២ពាន់លានរៀល ក្នុងរយៈពេល ៥ឆ្នាំ។

ផលសំរេចនៃ*កម្មវិធីអភិវឌ្ឍមន្ត្រីអប់រំ* មានវត្ថុបំណងចំបងគឺ បង្កើនគុណភាពនៃការបង្រៀន ឆ្លើយតបអោយកាន់តែច្រើនទៅនឹងការផ្លាស់ប្តូរតំរូវការគ្រូតាមអនុវិស័យ និងកែលំអការគ្រប់គ្រង និងផែនការកម្មហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រវិស័យអប់រំ។ សមាសភាគទី១ នៃកម្មវិធីនេះ គឺការផ្តល់សំភាររូបវ័ន្តសាលាគរុកោសល្យនិងវិក្រឹតការខ្នាតតូចនៅក្នុងខេត្ត-ក្រុងទាំង៦ដែលគ្មានសាលាគរុកោសល្យ និងវិក្រឹតការ ដើម្បីសំរួលដល់ការធ្វើវិក្រឹតការ បំប៉នគ្រូកំរិតមូលដ្ឋានតាមការចាំបាច់។ សមាសភាគទី២ គឺការកែលំអវិទ្យាស្ថានជាតិអប់រំ សាលាគរុកោសល្យ និងវិក្រឹតការខេត្ត-ក្រុង និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដើម្បីឆ្លើយតបប្រកបដោយភាពទន់ភ្លន់ជាងមុន ទៅនឹងការអភិវឌ្ឍមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងតំរូវការនៃការបណ្តុះបណ្តាលគ្រូទន្ទឹមគ្នានឹងការបំពាក់បន្ថែមនូវសំភាររូបវ័ន្ត និងបន្ទប់រៀនផ្នែកឯកទេស( ឧ. វិទ្យាសាស្ត្រ គណិតវិទ្យា បច្ចេកវិទ្យា ICT និងភាសាបរទេស) ។ ចំនាយសំរាប់កម្មវិធីនេះគឺ ៣៨ពាន់លានរៀល ក្នុងរយៈពេល ៥ឆ្នាំ។

ផលសំរេចនៃ*កម្មវិធីផ្តល់ផ្ទះស្នាក់នៅសំរាប់មន្ត្រីអប់រំ* គឺជួយសំរួលដល់ការបង្កើនការពង្រាយបុគ្គលិកនិងការរក្សាទុកបុគ្គលិក ជាពិសេសនៅតាមតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក តាមរយៈការផ្តល់រង្វាន់លើកទឹកចិត្ត ដោយរួមមានគំរោងផ្តល់ប្រាក់កំចីសំរាប់សាងសង់ផ្ទះស្នាក់នៅ និងផ្តល់ផ្ទះស្នាក់នៅដល់មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា សំរាប់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដែលបានធ្វើការផ្លាស់ប្តូរទីកន្លែងធ្វើការ ។ ចំនាយសំរាប់កម្មវិធីនេះ គឺ ២០ពាន់លានរៀលសំរាប់រយៈពេល ៥ឆ្នាំ។

ផលសំរេចនៃ*កម្មវិធីមូលនិធិអភិវឌ្ឍន៍សំភាររូបវ័ន្តនៅ TVET* គឺបង្កើនការជំរុញអោយសហគមន៍ និងសហគ្រាសនានា មានឪកាសអនុវត្តការបណ្តុះបណ្តាល។ សកម្មភាពជាចំបងរបស់កម្មវិធីនេះគឺ ផ្តល់ជំនួយឥតសំណងដល់ថ្នាក់ឃុំ ស្រុក សំរាប់អភិវឌ្ឍមជ្ឈមណ្ឌលសិក្សាសហគមន៍។ សកម្មភាពផ្សេងទៀតនោះគឺ ផ្តល់ការគាំទ្រដល់ការផ្តួចផ្តើមអោយមានការវិនិយោគពីផ្នែកឯកជនសំរាប់ TVET តាមរយៈការផ្តល់ប្រាក់កំចីដែលបានជ្រើសសំរាំង និងកំណត់ទុក។ កម្មវិធីនេះត្រូវអនុវត្តដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ចំណាយសំរាប់កម្មវិធីនេះគឺ ៤០ពាន់លានរៀល ក្នុងរយៈពេល ៥ឆ្នាំ។

ផលសំរេចនៃ*កម្មវិធីមូលនិធិអភិវឌ្ឍន៍សំភារៈរូបវ័ន្តនៅគ្រឹះស្ថានឧត្តមសិក្សា* គឺពង្រីកលទ្ធភាពចូលរៀនក្នុងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជននៅទូទាំងប្រទេស។ កម្មវិធីនេះគឺបង្កើតហិរញ្ញប្បទានអភិវឌ្ឍន៍គ្រឹះស្ថានឧត្តមសិក្សា សំរាប់ពង្រីកការចូលរៀនទាំងនៅគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ទន្ទឹមគ្នានឹងការអភិវឌ្ឍលក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើសនិស្សិតចូលរៀន។ ចំណាយសំរាប់កម្មវិធីនេះគឺ ៦០ពាន់លានរៀលក្នុងរយៈពេល៥ឆ្នាំ។

ផលសំរេចនៃ*កម្មវិធីកសាងសមត្ថភាពគ្រប់គ្រង និងពិនិត្យតាមដាន* គឺបន្តពង្រឹងសមត្ថភាពរបស់មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅរដ្ឋបាលកណ្តាល និងថ្នាក់ខេត្ត-ក្រុង ដើម្បីពិនិត្យតាមដាន និងវាយតំលៃការរីកចំរើន និងផលប៉ះពាល់នៃកំនែទំរង់អប់រំ។ សកម្មភាពចំបង១គឺ បន្តកែលំអដំណើរការបណ្តុះបណ្តាល និងកសាងសមត្ថភាពផ្សេង១ទៀត (ឧ. បង្កើនការប្រើប្រាស់ ICT) របស់មន្ត្រីនៅរដ្ឋបាលកណ្តាល និងខេត្ត-ក្រុង លើបច្ចេកទេសពិនិត្យតាមដាន និងវាយតំលៃ។ កម្មវិធីពិនិត្យតាមដាននេះ ត្រូវគ្រប់គ្រងដោយអង្គភាពគ្រប់គ្រងថវិការបស់នាយកដ្ឋានមួយចំនួនសំរាប់កម្មវិធីផ្សេង១គ្នា។ ការចំណាយសំរាប់កម្មវិធីនេះគឺ ៧៥ពាន់លានរៀល ក្នុងរយៈពេល ៥ឆ្នាំ។

ផលសំរេចនៃ*កម្មវិធីកសាងសមត្ថភាពគ្រប់គ្រងទូទាំងវិស័យ* គឺបន្តពង្រឹងប្រព័ន្ធផែនការកម្ម គ្រប់គ្រង និងពិនិត្យតាមដានកម្មវិធីជាអាទិភាពនានា។ ការកសាងសមត្ថភាពរួមបញ្ចូលទាំងការអភិវឌ្ឍអង្គភាពសំភារបរិក្ខារ ការជួយឧបត្ថម្ភធនធានផ្សេង១ទៀត សេវាកម្មផ្តល់យោបល់ និងកម្មវិធីបណ្តុះបណ្តាលសំរាប់រដ្ឋបាលកណ្តាល ខេត្ត-ក្រុង ស្រុក និងសាលារៀន។ អង្គភាពគ្រប់គ្រងថវិកាសំរាប់កម្មវិធីកសាងសមត្ថភាពគឺក្រុមសំរបសំរួលការកសាងសមត្ថភាព (CBCGs) នៅតាមអគ្គនាយកដ្ឋាននីមួយ១។ ចំនាយសំរាប់កម្មវិធីនេះគឺប្រហែល ៧៥ពាន់លានរៀល ក្នុងរយៈពេល ៥ឆ្នាំ។